**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ: ៣៥៩ សរណន.កសក

**សារាចរណែនាំ**

**ស្តីពី**

**ការពង្រីកសេវាព័ត៌មានទីផ្សារកសិកម្មដល់មូលដ្ឋានភូមិ ~ ឃុំ**

មកទល់នឹងបច្ចុប្បន្ននេះ សេវាព័ត៌មានទីផ្សារកសិកម្ម ដែលក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ បានប្រតិបត្តិកន្លងមក ត្រូវបានវាយតម្លៃខ្ពស់ក្នុងការបំពេញតួនាទី ជួយធ្វើឱ្យកសិកម្មមានមូលដ្ឋានត្រឹមត្រូវក្នុងការធ្វើផែនការផលិតកម្មរបស់របស់គាត់ និងសម្រេចជោគជ័យក្នុងផលិតកម្មកសិកម្មដែលឆ្លើយតបទៅនឹងតម្រូវការរបស់ទីផ្សារ សម្រួលដល់កសិករក្នុងការចរចាថ្លៃ និងអាចសម្រេចចិត្តក្នុងការលក់ផលិតផលឱ្យឈ្នះនៅលើទីផ្សារស្របតាមកាលានុវត្តិភាព ដែលអាចប្រមូលប្រាក់ចំណូលខ្ពស់ពីផលិតកម្មរបស់ខ្លួន ។ សេវាព័ត៌មានទីផ្សារកសិកម្មក៏បានជួយផងដែរដល់ពាណិជ្ជករ ឱ្យទទួលបានផលចំណេញ ក្នុងការសម្រេចចិត្តបញ្ជូនទំនិញ ពីកន្លែងដែលមានទំនិញ ច្រើនលើសលុប ទៅកាន់ទីផ្សារដែលត្រូវការ និងអាចធ្វើការសម្រេចចិត្តស្តុកឬលក់ទំនិញ ដើម្បីទទួលបានប្រាក់ចំណេញខ្ពស់ ។

កន្លងមក សេវាព័ត៌មានទីផ្សារកសិកម្ម ដែលក្រសួងបានអនុវត្ត បានគ្របដណ្តប់លើ រាជធានី ខេត្ត ចំនួន ១១ រួមមាន៖ រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តកំពង់ចាម ខេត្តតាកែវ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ ខេត្តកំពត ខេត្តកំពង់ឆ្នាំង និង ខេត្តព្រៃវែង និងបានធ្វើការផ្សព្វផ្សាយតាមរយៈវិទ្យុចំនួន ៨ ផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម តាមសេវាផ្ញើសារជាអក្សរ (Short Message Service-SMS) ប្រតិបត្តិព័ត៌មានទីផ្សារកសិកម្ម និងការផ្សព្វផ្សាយតាមប្រព័ន្ធវេបសាយ ។ ដោយសារថា កសិករភាគច្រើននៅតែត្រូវការព័ត៌មានទីផ្សារកសិកម្ម ពិសេសប្រជាកសិករតាមបណ្តាលភូមិ-ឃុំ ដាច់ស្រយាលនៅជនបទទូទាំងប្រទេស ការងារនេះ ទាមទារឱ្យមានការពង្រីកបន្ថែមទៀត ។

ដូចនេះ ក្នុងទិសដៅនិងយុទ្ធសាស្ត្រយូរអង្វែង សំដៅធ្វើឱ្យប្រសើរឡើងនូវកំរិតជីវភាពរស់នៅរបស់ប្រជាកសិករនៅទូទាំងប្រទេស តាមរយៈនៃការផ្តល់ព័ត៌មានទីផ្សារកសិកម្ម ឱ្យបានដល់គ្រប់មូលដ្ឋានភូមិ-ឃុំ ដោយប្រើប្រាស់គ្រប់មធ្យោបាយ និងរូបភាពចាត់តាំងនានា ពិសេសប្រព័ន្ធឃោសនាតាមរលកធាតុអាកាស និងតាមរយៈ មន្ទីរកសិកម្មរាជធានី ខេត្ត ការិយាល័យកសិកម្ម ក្រុង ស្រុក ខណ្ឌ និងបណ្តាញភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ទូទាំងប្រទេសនោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមធ្វើការណែនាំដល់គ្រប់អង្គភាពជំនាញថ្នាក់កណ្តាល មន្ទីរកសិកម្មរាជធានី ខេត្ត ទូទាំងប្រទេស ត្រូវជំរុញអនុវត្តនូវសកម្មភាពជាក់ស្តែងមួយចំនួនចំពោះមុខដូចខាងក្រោម៖

១- នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវបន្តនិងពង្រីកសកម្មភាពប្រមូល និងផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម ដោយរួមជាមួយមន្ត្រីទីផ្សារកសិកម្មនៅទូទាំង ២៤ រាជធានី ខេត្ត ។ ត្រូវបន្តនិងពង្រីកការផ្សព្វផ្សាយតាមវិទ្យុ នឹងរៀបចំព្រឹត្តប័ត្រព័ត៌មានទីផ្សារកសិកម្មប្រចាំខែ-ប្រចាំឆ្នាំ និង បោះពុម្ពសម្រាប់ការការចែកផ្សាយ ដល់អង្គភាពជំនាញថ្នាក់កណ្តាល មន្ទីរកសិកម្មរាជធានី ខេត្ត និងការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ។

២- នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវរៀបចំផែនការបង្កើនសមត្ថភាពមន្ត្រីរាជការ និងបើកវគ្គបណ្តុះបណ្តាល ក៏ដូចជាវគ្គបំពាក់បំប៉នជំនាញទីផ្សារកសិកម្ម ដល់មន្ត្រីទីផ្សារកសិកម្មនៃមន្ទីរកសិកម្ម រាជធានី ខេត្ត ដើម្បីឱ្យមន្ត្រីទាំងនោះ អាចមានសមត្ថភាពក្នុងការអនុវត្តការងារផ្តល់សេវាព័ត៌មាន ទីផ្សារកសិកម្ម ។

៣- នាយកដ្ឋានបានផ្សព្វផ្សាយកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម ត្រូវយកចិត្តទុកដាក់និងចូលរួមក្នុងការផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម ឱ្យដល់មូលដ្ឋានភូមិ-ឃុំ តាមរយៈបណ្តាលមន្ត្រីផ្សព្វផ្សាយកសិកម្មក្រុង ស្រុក ខណ្ឌ និងភ្នាក់ងារផ្សព្វផ្សាយកសិកម្មភូមិ ។ នាយកដ្ឋានផ្សព្វផ្សាយកសិកម្មត្រូវទំនាក់ទំនង នាយកដ្ឋានផែនការ និងស្ថិតិ ដើម្បីយកព័ត៌មានទីផ្សារកសិកម្ម និងបញ្ចូលទៅក្នុងកម្មវិធីផ្សាយតាមទូរទស្សន៍ជាតិកម្ពុជា រៀងរាល់សប្តាហ៍ ។

៤- មជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្ម និង នាយកដ្ឋានផែនការ និងស្ថិតិ ត្រូវរួមសហការគ្នាក្នុងការផ្សព្វផ្សាយព័ត៌មានទីផ្សារកសិកម្ម តាមរយៈគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ឱ្យបានទៀងទាត់ និងធានាបច្ចុប្បន្នភាពនៃព័ត៌មានប្រចាំ ។

៥- មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តខ្លឹមសារនៃលិខិតលេខ ២៧៤០ កសក ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៨ ស្តីពីការបង្កើតផ្នែក “ទីផ្សារកសិកម្ម” នៅចំណុះការិយាល័យ

ផែនការ-គណនេយ្យរបស់មន្ទីរ និងត្រូវរៀបចំចាត់តាំងមន្ត្រីជំនាញទទួលបន្ទុកការងារនេះ ឱ្យបាន ច្បាស់លាស់ ដើម្បីងាយស្រួលក្នុងការអនុវត្តការងារផ្នែកទីផ្សារកសិកម្ម ។

៦- មន្ទីរកសិកម្ម រាជធានី ខេត្ត ត្រូវជំរុញអនុវត្ត និងបន្តការងារប្រមូលព័ត៌មានទីផ្សារកសិកម្ម រួចផ្សព្វផ្សាយនៅតាមស្ថានីយ៍វិទ្យុក្នុងខេត្តរបស់ខ្លួន ។ ព័ត៌មានទីផ្សារកសិកម្ម ដែលមន្ទីរកសិកម្ម រាជធានី ខេត្ត ប្រមូលបានត្រូវបញ្ជូនទៅការិយាល័យកសិកម្មក្រុង ស្រុក ខណ្ឌ ដើម្បីធ្វើការ ផ្សព្វផ្សាយបន្តដោយមន្ត្រីផ្សព្វផ្សាយក្រុង ស្រុក ខណ្ឌ តាមរយៈការបិទផ្សាយព័ត៌មាន ទីផ្សារនៅតាមក្តារខៀនផ្សព្វផ្សាយព័ត៌មានតាមឃុំ-សង្កាត់-ភូមិ ។ ព័ត៌មានទីផ្សារកសិកម្ម ដែលមន្ទីរកសិកម្ម រាជធានី ខេត្ត ប្រមូលបាន ក៏ត្រូវបញ្ជូនមកក្រសួង (នាយកដ្ឋានផែនការនិងស្ថិតិ) សម្រាប់បញ្ចូលក្នុងព័ត៌មានទីផ្សារកសិកម្ម និង ផ្សព្វផ្សាយបន្តតាមគ្រប់រូបភាព ។

៧- នាយកដ្ឋានផែនការនិងស្ថិតិ និង មន្ទីរកសិកម្មរាជធានី ខេត្ត ត្រូវរៀបចំលើកគំរោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ដោយប្រើប្រាស់ថវិកាជាតិ សម្រាប់គាំទ្រដល់ការអនុវត្តការងារផ្តល់សេវាព័ត៌មាន ទីផ្សារកសិកម្ម និងត្រូវសម្របសម្រួលកៀងគរជំនួយដើម្បីអនុវត្តផែនការសកម្មភាពសេវាព័ត៌មាន ទីផ្សារកសិកម្ម ឱ្យទទួលបានលទ្ធផលល្អ និង មានប្រសិទ្ធភាពខ្ពស់ ។

ទទួលបាននូវសារាចរណែនាំនេះ គ្រប់អង្គភាពជំនាញថ្នាក់កណ្តាល ក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និង គ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត ទូទាំងប្រទេស ត្រូវទទួលខុសត្រូវ ចាត់វិធានការអនុវត្តតាម ខ្លឹមសារសារាចរណែនាំនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៩

**រដ្ឋមន្ត្រី**

**ចន្ទ័ សារុន**

**<u>កន្លែងទទួល :</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ផែនការ
- ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួង ព័ត៌មាន
- ក្រសួង ពាណិជ្ជកម្ម
- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អង្គភាពក្រោមឱវាទក្រសួងដែលពាក់ព័ន្ធ
- គ្រប់មន្ទីរកសិកម្ម រាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយ ៖ លោក ឈឹម ទីណា